របៀបរៀបចំការណាត់ជួបសម្រាប់អាជ្ញាប័ណ្ណអ្នកសិក្សា (Learner's Permit)

អាជ្ញាប័ណ្ណអ្នកសិក្សា (Learner's Permit) គឺជាជំហានដំបូងឆ្ពោះទៅប័ណ្ណបើកបររដ្ឋ Massachusetts

តើអ្នកត្រូវការអាជ្ញាប័ណ្ណអ្នកសិក្សា (Learner's Permit) ឬទេ?

- អាជ្ញាប័ណ្ណអ្នកសិក្សា (Learner's Permit) ផ្តល់ជូនអ្នកនូវការចេញអាជ្ញាប័ណ្ណដើម្បីបើកបរស្របច្បាប់នៅរដ្ឋ Massachusetts នៅខណៈពេលលោកអ្នកអនុវត្តជំនាញបើកបររបស់អ្នក និងត្រៀមការធ្វើតេស្តផ្លូវរបស់អ្នក។

លោកអ្នកត្រូវការចំណុចដូចខាងក្រោម ដើម្បីដាក់ពាក្យសុំអាជ្ញាប័ណ្ណអ្នកសិក្សា (Learner's Permit)៖

- ☑ ***ប័ណ្ណបើកបរ (Driver's License)*** ដែលបានបំពេញ, ***អាជ្ញាប័ណ្ណអ្នកសិក្សា (Learner's Permit),*** ឬសំណុំបែបបទ ***ពាក្យសុំអត្តសញ្ញាណប័ណ្ណ (ID Card Application)***
- ☑ ត្រូវមានអាយុយ៉ាងតិច 16 ឆ្នាំ។
- ☑ លិខិតបញ្ជាក់ការស្នាក់នៅរដ្ឋ Massachusetts (2 សម្រាប់អាជ្ញាប័ណ្ណ/ប័ណ្ណបើកបរ ឬ 1 សម្រាប់ អាជ្ញាប័ណ្ណ/ប័ណ្ណបើកបរស្តង់ដារ)
- ☑ លិខិតបញ្ជាក់វត្តមានស្របច្បាប់ (អាជ្ញាប័ណ្ណបើកបរឬអត្តសញ្ញាណប័ណ្ណ (REAL ID Permits) /លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណពាណិជ្ជកម្ម ស្តង់ដារ) ឬលិខិតបញ្ជាក់អត្តសញ្ញាណ និងថ្ងៃខែឆ្នាំកំណើត (អ្នកដំណើរស្តង់ដារ (ប្រភេទ D) ឬម៉ូតូ (ប្រភេទ M) អាជ្ញាប័ណ្ណ/ប័ណ្ណបើកបរ)
- ☑ លិខិតបញ្ជាក់ស្ថានភាពនិងលេខធានារ៉ាប់រងសង្គមកិច្ច

<u>សូមកត់សម្គាល់៖</u>

- ឯកសារទាំងអស់ត្រូវតែជាឯកសារដើម; ឯកសារថតចម្លងមិនទទួលយកទេ។ ឯកសារអាចមិនមានរបក។ ឯកសារណាមួយដែលមិនមែនជា ភាសាអង់គ្លេស ត្រូវតែភ្ជាប់មកជាមួយឯកសារបកប្រែភាសាដែលមានលិខិតបញ្ជាក់។
- អាជ្ញាប័ណ្ណអ្នកសិក្សា (Learner's Permit) មានសុពលភាពរយៈពេល 2 ឆ្នាំ។ ប្រសិនបើអាជ្ញាប័ណ្ណរបស់អ្នកផុតកំណត់ លោកអ្នកត្រូវដាក់ពាក្យសុំម្តងទៀត ហើយប្រឡងចំណេះដឹងឡើងវិញ។

ព័ត៌មានសំខាន់ៗ

តើអ្នកជាអ្នកបើកបរលើកដំបូងមែនទេ?

- គេហទំព័រ Mass.Gov/RMV រួមបញ្ចូលការណែនាំជាជំហានៗដែលពន្យល់អំពីដំណើរការដាក់ពាក្យសុំ អាជ្ញាប័ណ្ណអ្នកសិក្សានិងប័ណ្ណបើកបរ (ប្រភេទ D) សម្រាប់អ្នកដំណើរ។ ជំហាននានាដើម្បីទទួលបាន ប័ណ្ណបើកបរ ព័ត៌មានមាតាបិតា/អាណាព្យាបាល ការណែនាំអំពីការបើកបរប្រកបដោយសុវត្ថិភាព ក៏ដូចជាឯកសារសិក្សាត្រូវបានរួមបញ្ចូលផងដែរ។ សូមចូលមើលវិបសាយ https://www.mass.gov/guides/first-time-driver-start-here

<u>សូមអនុវត្តតាមជំហានខាងក្រោម ដើម្បីរៀបចំការណាត់ជួបសម្រាប់អាជ្ញាប័ណ្ណអ្នកសិក្សា៖</u>

Step #1: ស្វែងរកគេហទំព័រ myRMV Online Service Center.

សូមជ្រើសរើសតំណភ្ជាប់នេះ Mass.Gov/MyRMV ដើម្បីចូលទៅគេហទំព័រដោយផ្ទាល់ ឬបើកកម្មវិធីរុករកថ្មីមួយ ហើយបញ្ចូល *mass.gov/myRMV* ទៅក្នុងរបារអាសយដ្ឋាន។

- ***សម្គាល់៖*** សម្រាប់ការចុះបញ្ជីយានយន្តរដ្ឋម៉ាសាជូសេត (Registry of Motor Vehicles, RMV) សូមចូលមើលគេហទំព័រសំខាន់ៗ Mass.Gov/RMV.

Step #2: ជ្រើសរើសដាក់ពាក្យសុំអាជ្ញាប័ណ្ណអ្នកសិក្សា (Prepare for a Learner's Permit) នៅក្នុងផ្ទាំងណែលប័ណ្ណបើកបរ និង អាជ្ញាប័ណ្ណអ្នកសិក្សា (Driver's License and Learner's Permit)។



Step #3: ជ្រើសរើសប្រភេទអាជ្ញាប័ណ្ណដែលអ្នកចង់ដាក់ពាក្យសុំ។

- ឧទាហរណ៍សូមជ្រើសរើស**អាជ្ញាប័ណ្ណអ្នកដំណើរប្រភេទ D (Class D Passenger Permit)**។



Step #4: ឆ្លើយសំណួរអំពីលិខិតបញ្ជាក់នៅរដ្ឋម៉ាសាជូសេត (Massachusetts Credential)។ ជ្រើសរើសបន្ត (Continue)។

- ប្រសិនបើលោកអ្នកធ្លាប់កាន់លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ឬអត្តសញ្ញាណប័ណ្ណ ID រដ្ឋ Massachusetts ពីមុនមក សូមឆ្លើយ បាទ/ចាស់ **(Yes)** ចំពោះសំណួរទីមួយ។
- ប្រសិនបើបច្ចុប្បន្នលោកអ្នកមានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬអត្តសញ្ញាណប័ណ្ណ ID នៅក្រៅរដ្ឋ សូមឆ្លើយថា បាទ/ចាស់ **(Yes)** ចំពោះសំណួរទីពីរ។



Step #5: ពិនិត្យឡើងវិញព័ត៌មានប្រតិបត្តិការ (Transaction Information) នៅទំព័រត្រៀមខ្លួនជាស្រេច (Get Ready)។ ជ្រើសរើស បន្ទាប់ (Next)។



Step #6: ជ្រើសរើស ប័ណ្ណបើកបរឬអត្តសញ្ញាណប័ណ្ណ(REAL ID), អត្តសញ្ញាណប័ណ្ណស្តង់ដារ (Standard ID) ឬទម្រង់នៅទំព័រអត្តសញ្ញាណប័ណ្ណបណ្តឹងតវ៉ាសហព័ន្ធ (Federally Compliant ID)។ ជ្រើសរើសបន្ទាប់ (Next) ដើម្បីបន្តដំណើរការ។

- ឧទាហរណ៍ជ្រើសរើស**អាជ្ញាប័ណ្ណ/អត្តសញ្ញាណ ID តាមស្តង់ដាររដ្ឋម៉ាសាជូសេត (Standard Massachusetts License/ID)**។



Step #7: បំពេញចំណុចទាំងអស់នៅទំព័រ *ព័ត៌មានអត្តសញ្ញាណ (Identification Information)*។ ជ្រើសរើស *បន្ទាប់ (Next)*។

- ជ្រើសរើស**ប្រភេទអត្តសញ្ញាណ (ID Type)** ដែលអនុវត្តចំពោះអ្នកពីបញ្ជីទម្លាក់ចុះ។ បញ្ចូលលេខនៅ ចំណុចខាងក្រោម។
  - ***សម្គាល់***៖ អ្នកដាក់ពាក្យសុំដែលមានលេខប័ណ្ណជានាវ៉ាប់រងសង្គមកិច្ច (SSN) ត្រូវតែផ្តល់ជូនលេខប័ណ្ណ SSN របស់ពួកគេសម្រាប់ការផ្ទៀងផ្ទាត់តាមអនឡាញ។



Step #8: បញ្ចូលអាសយដ្ឋានស្នាក់នៅរបស់អ្នកនៅផ្នែកខាងលើនៃទំព័រ *ព័ត៌មានអាសយដ្ឋាន (Address Information)*។

- លោកអ្នកត្រូវតែបញ្ចូលអាសយដ្ឋានផ្លូវជាអាសយដ្ឋានស្នាក់នៅរបស់អ្នក។ ប្រអប់ប៉ុស្តប្រៃសណីយ៍ (Post Office Box) ឬអាសយដ្ឋាន "ជូនចំពោះអ្នកទទួល" មិនអាចប្រើសម្រាប់អាសយដ្ឋានស្នាក់នៅបានទេ។



Step #9: បញ្ចូលអាសយដ្ឋានប៉ុស្តប្រៃសណីយ៍ (Mailing Address) របស់អ្នក។ ជ្រើសរើស *បន្ទាប់ (Next)* ដើម្បីបន្តដំណើរការ។

ឆ្លើយសំណួរ *"តើអាសយដ្ឋានប៉ុស្តប្រៃសណីយ៍របស់អ្នកដូចគ្នានឹងអាសយដ្ឋានស្នាក់នៅរបស់អ្នក" ("Is your mailing address the same as your residential address?") ឬទេ?"*

- ជ្រើសរើសចម្លើយ ***បាទ/ចាស់ (Yes)*** បើអាសយដ្ឋានប៉ុស្តប្រៃសណីយ៍របស់អ្នកដូចគ្នានឹងអាសយដ្ឋានស្នាក់នៅរបស់អ្នក។



- ជ្រើសរើសចម្លើយ ***ទេ (No)*** បើអាសយដ្ឋានប៉ុស្តប្រៃសណីយ៍របស់អ្នកខុសគ្នានឹងអាសយដ្ឋានស្នាក់នៅរបស់អ្នក។
  - បញ្ចូលអាសយដ្ឋានប៉ុស្តប្រៃសណីយ៍បច្ចុប្បន្នរបស់អ្នកនៅក្នុងចំណុចដែលបង្ហាញ។
  - ប្រអប់ប៉ុស្តប្រៃសណីយ៍ (Post Office Box) អាចប្រើជាអាសយដ្ឋានប៉ុស្តប្រៃសណីយ៍។



Step #10: ផ្ទៀងផ្ទាត់ និងជ្រើសរើសអាសយដ្ឋានស្តង់ដារ (USPS-standardized address) របស់អ្នក។ ជ្រើសរើស *បន្ទាប់ (Next)* ដើម្បីបន្តដំណើរការ



Step #11: *បញ្ចូលអាសយដ្ឋានអ៊ីម៉ែល និងលេខទូរស័ព្ទនៅទំព័រ ព័ត៌មានទំនាក់ទំនង (Contact Information)។ ជ្រើសរើស បន្ទាប់ (Next) ដើម្បីបន្តដំណើរការ។*

ផ្នែកជាន់ណែលព័ត៌មានទំនាក់ទំនងបឋម (Primary Contact Information)៖

- ជ្រើសរើស **បន្ថែមទំនាក់ទំនងផ្សេងទៀត (Add Another Contact)** ដើម្បីបញ្ចូលអាសយដ្ឋានអ៊ីម៉ែលទីពីរ។

ផ្នែកជាន់ណែលព័ត៌មានទំនាក់ទំនងសង្គ្រោះបន្ទាន់ (Emergency Contact Information)៖

- ជ្រើសរើស **បាទ/ចាស៎ (Yes)** ដើម្បីបញ្ចូលឈ្មោះទំនាក់ទំនងសង្គ្រោះបន្ទាន់ អាសយដ្ឋានអ៊ីម៉ែល និងលេខទូរស័ព្ទ។
- ជ្រើសរើស **ទេ (No)** ប្រសិនបើអ្នកមិនចង់បញ្ចូលទំនាក់ទំនងសង្គ្រោះបន្ទាន់។



Step #12: *បំពេញចំណុចដែលទាមទារទាំងអស់នៅទំព័រ ព័ត៌មានប្រជាពលរដ្ឋ (Demographic Information)។ ជ្រើសរើស បន្ទាប់ (Next) ដើម្បីបន្តដំណើរការ។*

ផ្ទាំងជានណេល**ព័ត៌មានប្រជាសាស្ត្រ (Demographic Information)**

- ជ្រើសរើសសញ្ញាព្រួញដើម្បីបើកបញ្ជីទម្លាក់ចុះសម្រាប់**យេនឌ័រ (Gender)** និង**ពណ៌ភ្នែក (Eye Color)**។ ជ្រើសរើសជម្រើសត្រឹមត្រូវពីបញ្ជីនីមួយៗ។
- បញ្ចូលកម្ពស់របស់អ្នកនៅក្នុងចំណុច**កម្ពស់ (ហ្វីត) (Height (feet))** និង**កម្ពស់ (អ៊ីញ) (Height (inches))**។

ផ្ទាំងជានណេល**ព័ត៌មានព័ត៌មានយោធា (Military Information)**

- ជ្រើសរើស **បាទ/ចាស៎ (Yes)**
  ប្រសិនបើអ្នកជាសមាជិកកាតព្វកិច្ចសកម្មនៃកងកម្លាំងប្រដាប់អាវុធសហរដ្ឋអាមេរិក។
  - ជ្រើសរើសសញ្ញាព្រួញដើម្បីជ្រើសរើសចម្លើយចំពោះសំណួរបន្ថែមដែលបង្ហាញ។
- ជ្រើសរើស **ទេ (No)**
  ប្រសិនបើអ្នកមិនមែនជាសមាជិកកាតព្វកិច្ចសកម្មនៃកងកម្លាំងប្រដាប់អាវុធសហរដ្ឋអាមេរិក។

ផ្ទាំងជានណេលអ្នកបរិច្ចាគសរីរាង្គនិងជាលិកា (Organ and Tissue Donor)៖

- ជ្រើសរើស **បាទ/ចាស៎ (Yes)** ឬ **ទេ (No)** ក្នុង***ការចុះឈ្មោះខ្ញុំជាអ្នកបរិច្ចាគសរីរាង្គនិងជាលិកា (Register me as an Organ and Tissue Donor)***។



Step #13: បញ្ជាក់ឯកសារដែលអ្នកនឹងផ្តល់ជូននៅទំព័រ*ឯកសារបញ្ជាក់ (Proof Documents)*។

ទំព័រនេះបញ្ជាក់ឯកសារណាដែលអាចទទួលយកបាន
និងទាមទារដោយផ្អែកលើជម្រើសប័ណ្ណបើកបរស្តង់ដារ ឬ ប័ណ្ណបើកបរឬអត្តសញ្ញាណប័ណ្ណ (REAL ID) របស់អ្នក។

- ជ្រើសរើសសញ្ញាព្រួញសម្រាប់តម្រូវការទាមទារនីមួយៗ ដើម្បីបើកបញ្ជីទម្លាក់ចុះពីជម្រើសដែលអាចទទួលយកបាន; ជ្រើសរើសឯកសារដែលអ្នកនឹងផ្តល់ជូន។

<u>បើសិនបើអ្នកកំពុងដាក់ពាក្យសុំអាជ្ញាប័ណ្ណអ្នកសិក្សាដែលមានប័ណ្ណបើកបរឬអត្តសញ្ញាណប័ណ្ណ (REAL ID Learner's Permit) ឬអាជ្ញាប័ណ្ណអ្នកសិក្សាផ្នែកពាណិជ្ជកម្មស្តង់ដារ (Standard Commercial Learner's Permit)៖</u>

- សូមផ្តល់ជូនឯកសារដូចខាងក្រោម៖
  - លិខិតបញ្ជាក់លេខប័ណ្ណជានាវ៉ាប់រងសង្គមកិច្ច (Social Security Number, SSN)

- ***សម្គាល់៖*** សម្រាប់លិខិតអនុញ្ញាតស្តង់ដារ (Standard CDL permits), អ្នកដាក់ពាក្យសុំគ្រាន់តែផ្តល់ជូនលេខប័ណ្ណជានារ៉ាប់រងសង្គមកិច្ច (Social Security Number, SSN) ដែលអាចផ្លៀងផ្ទាត់បាន (មិនត្រូវការឯកសារប័ណ្ណ SSN)។
  - ទី 1 លិខិតបញ្ជាក់ការស្នាក់នៅ និងទី 2 លិខិតបញ្ជាក់ការស្នាក់នៅ
    - បញ្ជីឯកសារដែលអាចទទួលយកបានគឺដូចគ្នាសម្រាប់តម្រូវទាមទារការស្នាក់នៅទាំងពីរ។
    - ឯកសារខ្លះមានការកំណត់ពេលវេលាដែលអាចទទួលយកបាន (ឧទាហរណ៍ក្នុងរយៈពេល 60 ថ្ងៃ)។
    - ***សម្គាល់៖*** សម្រាប់លិខិតអនុញ្ញាតស្តង់ដារ (Standard CDL permits) តម្រូវឱ្យមានលិខិត បញ្ជាក់ការស្នាក់នៅតែ 1 ច្បាប់ប៉ុណ្ណោះ។
  - លិខិតបញ្ជាក់វត្តមានស្របច្បាប់
    - ***សម្គាល់៖***
      ប្រសិនបើឈ្មោះបច្ចុប្បន្នរបស់អ្នកមិនត្រូវគ្នានឹងឈ្មោះនៅក្នុងឯកសារវត្តមានស្របច្បាប់ របស់អ្នកទេ អ្នកត្រូវផ្តល់ឯកសារផ្តាសប្តរឈ្មោះស្របច្បាប់ (សំបុត្រអាពាហ៍ពិពាហ៍ លិខិតបញ្ជាក់ លែងលះ/ប្តីប្រពន្ធ ឬឯកសារតុលាការ)
      ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់លិខិតបញ្ជាក់ ប័ណ្ណបើកបរឬអត្តសញ្ញាណប័ណ្ណ (REAL ID credential)។
    - បំពេញចំណុចដែលត្រូវការបន្ថែម ដោយផ្អែកលើឯកសារដែលបានជ្រើសរើស។
- នៅពេលព័ត៌មានទាំងអស់ត្រូវបានបញ្ចូលត្រឹមត្រូវហើយ សូមជ្រើសរើសតំណភ្ជាប់**ផ្ទៀងផ្ទាត់វត្តមានស្របច្បាប់របស់ខ្ញុំ (Verify My Lawful Presence)** ដែលបង្ហាញនៅខាងក្រោមទំព័រនេះ។
  - សារដែលបង្ហាញថាការផ្ទៀងផ្ទាត់កំពុងដំណើរការ ឬព័ត៌មានអំពីវត្តមានស្របច្បាប់ មិនត្រូវបានរកឃើញ អាចបង្ហាញបានទេ។
- ជ្រើសរើស **បន្ទាប់ (Next)** ដើម្បីបន្តដំណើរការ។



ប្រសិនបើអ្នកកំពុងដាក់ពាក្យសុំអាជ្ញាប័ណ្ណអ្នកសិក្សាស្តង់ដារប្រភេទ D ឬ M (Standard Class D or M Learner's Permit)៖

- សូមផ្តល់ជូនឯកសារដូចខាងក្រោម៖
  - លិខិតបញ្ជាក់ការស្នាក់នៅ (ឯកសារមួយ)
    - ឯកសារខ្លះមានការកំណត់ពេលវេលាដែលអាចទទួលយកបាន (ឧទាហរណ៍ក្នុងរយៈពេល 60 ថ្ងៃ)។
  - លិខិតបញ្ជាក់គ្មានលេខប័ណ្ណ SSN
    - ផ្តល់លិខិតបញ្ជាក់គ្មានលេខប័ណ្ណ SSN ឬលិខិតបដិសេធលេខ SSN។
    - ***សម្គាល់៖*** ប្រសិនបើអ្នកបានផ្តល់លេខប័ណ្ណជានារ៉ាប់រងសង្គមកិច្ច (Social Security Number, SSN) ក្នុងជំហាន #7 ជម្រើសនេះ នឹងមិនបង្ហាញទេ។ លិខិតបញ្ជាក់គ្មាន

លេខប័ណ្ណ SSN
អាចប្រើបានសម្រាប់តែអតិថិជនដែលបង្ហាញឯកសារបញ្ជាក់មួយចំនួន
សម្រាប់ការបញ្ជាក់អត្តសញ្ញាណ និងថ្ងៃខែឆ្នាំកំណើតប៉ុណ្ណោះ។

- លិខិតបញ្ជាក់អត្តសញ្ញាណ និងថ្ងៃខែឆ្នាំកំណើត
  - ***សម្គាល់៖*** តម្រូវឱ្យមាន**លិខិតបញ្ជាក់អត្តសញ្ញាណបន្ទាប់បន្សំ និងថ្ងៃខែឆ្នាំកំណើត**
    ប្រសិនបើលិខិតឆ្លងដែនបរទេស ឬអត្តសញ្ញាណប័ណ្ណ ID
    កងស៊ុលដែលមិនទាន់ផុតកំណត់ ត្រូវបានផ្តល់ជូនជា**លិខិតបញ្ជាក់អត្តសញ្ញាណ និងថ្ងៃខែឆ្នាំកំណើត។**



Step #14: ឆ្លើយតបទៅនឹងសំណួរដែលត្រូវការទាំងអស់នៅទំព័រ ***ការចុះឈ្មោះអ្នកបោះឆ្នោត/ព័ត៌មានអ្នកបោះឆ្នោត (Voter Registration/Information)*** ។ ជ្រើសរើស **បន្ទាប់ (Next)** ដើម្បីបន្តដំណើរការ។



Step #15: ឆ្លើយ *សំណួរចាំបាច់ (Mandatory Questions)* ទាំងអស់។ ជ្រើសរើស *បន្ទាប់ (Next)* ដើម្បីបន្តដំណើរការ។



Step #16: ជ្រើសរើសប៊ូតុងបិទបើកនៅទំព័រ ***ការបញ្ជាក់អ្នកដាក់ពាក្យ (Certification of Applicant)*** ។ ជ្រើសរើស ***បន្ទាប់ (Next)*** ដើម្បីបន្តដំណើរការ។



Step #17: ពិនិត្យឡើងវិញចំនួនទឹកប្រាក់ដែលដល់ពេលបង់នៅទំព័រ ***សង្ខេបថ្លៃសេវា (Fees Summary)*** ។ ជ្រើសរើស ***បន្ទាប់ (Next)*** ។

- ថ្លៃសេវា**អាជ្ញាប័ណ្ណ (License)** និង**ថ្លៃសេវាធ្វើតេស្តផ្លូវ (Road Test)** ដែលបានរាយបញ្ជីក្នុងផ្ទាំងជាន់ណែល ***PrePay (ដែលមានជម្រើស) (PrePay (Optional))*** អាចបង់ប្រាក់ជាមួយថ្លៃសេវាពាក្យសុំអាជ្ញាប័ណ្ណ (Permit Application) ឬបន្ទាប់ពីលោកអ្នកឆ្លងកាត់ការធ្វើតេស្តផ្លូវ។
  - អាជ្ញាប័ណ្ណរបស់អ្នកមិនត្រូវបានចេញទេ រហូតដល់បានបង់ថ្លៃសេវាទាំងនេះ។
- ថ្លៃសេវា**ពាក្យសុំអាជ្ញាប័ណ្ណ (Permit Application)** ដែលបានរាយបញ្ជីក្នុងតារាង**ថ្លៃសេវាដល់ពេលកំណត់ (Fees Due)** ដែលត្រូវបង់ប្រាក់មុនពេលការប្រឡងចំណេះដឹងអាចត្រូវបានធ្វើឡើង។



Step #18: ពិនិត្យឡើងវិញ *ជំហានបន្ទាប់ (Next Steps) និងឯកសារនិងវិធានការដែលត្រូវការ (Required Documents and Actions)* ដែលបង្ហាញនៅទំព័រព័ត៌មានមជ្ឈមណ្ឌលសេវាកម្ម **(Service Center Information)**។ ជ្រើសរើស *បន្ទាប់ (Next)* ដើម្បីបន្តដំណើរការ។



Step #19: ពិនិត្យឡើងវិញព័ត៌មានទាំងអស់នៅទំព័រ *សង្ខេប (Summary)*។ ជ្រើសរើស *បញ្ជូន (Submit)* ដើម្បីបន្តដំណើរការ។

- ប្រសិនបើមានអ្វីមួយមិនត្រឹមត្រូវ ឬត្រូវការផ្លាស់ប្តូរ សូមជ្រើសរើសតំណភ្ជាប់ (hyperlink) ដែលសមរម្យនៅ ផ្នាំងផានណេលរុកវ៉ក់ខាងឆ្វេង។
  - ធ្វើការកែសម្រួលដែលចាំបាច់។
  - ជ្រើសរើស **បន្ទាប់ (Next)** ដើម្បីបន្តដំណើរការតាមរយៈទំព័រនីមួយៗ ហើយត្រឡប់ទៅទំព័រ**សង្ខេប (Summary)**។



Step #20: ពិនិត្យមើលនិងបោះពុម្ពទំព័រ *ពាក្យសុំ/ការបញ្ជាក់ (Application/Confirmation)*។

- ជ្រើសរើស**ពិនិត្យមើលដែលអាចបោះពុម្ពបាន (Printable View)**នៅទំព័រ**ការបញ្ជាក់ (Confirmation)** ដើម្បីបើកវានៅក្នុងផ្ទាំងកម្មវិធីរុករកផ្សេងទៀត។



- បោះពុម្ពទំព័រ**ពាក្យសុំ/ការបញ្ជាក់ (Application/Confirmation)**។
  - លេខកូដ (QR code) និងលេខបញ្ជាក់ (Confirmation Number) បង្ហាញនៅជ្រុងខាងស្តាំខាងលើ; កូដរបារ (bar code) បង្ហាញនៅខាងស្តាំខាងក្រោមនៃទំព័រ។
  - ប្រសិនបើលោកអ្នកមិនមានសិទ្ធិចូលប្រើមាស៊ុនបោះពុម្ពទេ សមាជិកនៃបុគ្គលិក RMV នឹងបោះពុម្ពទំព័រនេះ សម្រាប់លោកអ្នកនៅពេលលោកអ្នកមកដល់សម្រាប់ការណាត់ជួបមជ្ឈមណ្ឌលសេវាកម្មរបស់អ្នក។
- ចុះហត្ថលេខា និងកាលបរិច្ឆេទក្នុងចន្លោះដែលបានផ្តល់ជូន ហើយនាំយកទៅការណាត់ជួបនៅមជ្ឈមណ្ឌល សេវាកម្មរបស់អ្នក។ ឯកសារដែលបានបោះពុម្ពនេះ ដំណើរការជាការដាក់ពាក្យសុំអាជ្ញាប័ណ្ណអ្នកសិក្សា (Learner's Permit) របស់អ្នកដែលបានបំពេញ។



សូមអបអរសាទរ! លោកអ្នកបានចាប់ផ្តើមការដាក់ពាក្យសុំរបស់អ្នកដោយជោគជ័យសម្រាប់អាជ្ញាប័ណ្ណអ្នកសិក្សា **(MA Learner's Permit)**។

- ធ្វើការណាត់ជួបមជ្ឈមណ្ឌលសេវាកម្ម ដើម្បីបំពេញការដាក់ពាក្យសុំអាជ្ញាប័ណ្ណអ្នកសិក្សារបស់អ្នក។